# ១

## ហ្វូងចចកក្រុង

ពេលទៀបភ្លឺនៃរាត្រីមួយក្នុងខែឧសភាឆ្នាំ ១៩៧៣ មានព្រឹត្តិការណ៍មួយកើតឡើងនៅលើដងទន្លេមេគុង ក្នុងទឹកដីស្រុកលើកដែក ខេត្តកណ្ដាល។ ស្ថិតក្នុងវេនរនោចហោចណាស់ទៅហើយផ្ទៃមេឃប្រែជ្រះស្រឡះ ដោយពន្លឺដួងតារាបញ្ចេញការស្ទើរព្រាត ៗ ដូចផ្កាទន្ទះត្រាប់ពេជ្រនិងចំណិតព្រះចន្ទមានសណ្ឋានជារាងផ្លែកណ្ដៀវដែលទើបនឹងងើតផុតពីចុងព្រៃនៃទិសបូព៌ា។ពេលថ្មើរនោះសត្វសត្ថនិករកំពុងនិទ្រាលង់លក់ស្កប់ស្កល់ ពុំទាន់ដល់ពេលក្រោកចាកទ្រនំស្វែងរកចំណីពៀងជីពផងឡើយ ។ ប៉ុន្តែនៅលើផ្ទៃមេគុង មានស្រមោលខ្មៅមួយហ្វូងកំពុងធ្វើចលនាបណ្ដែតខ្លួនសំដៅមកកាន់ត្រើយខាងស្ដាំ ។ ទឹកដីស្រុកលើកដែកស្ថិតនៅក្នុងអាថ៌កំបាំង . . . ។

ដំណើរចុងរាត្រីនាំមកនូវភាពត្រជាក់ស្រេង ខ្យល់ផាត់ស្លឹកឈើលើមាត់ច្រាំងលាន់ឮស្រាវ ៗ លាយឡំនឹងស្នូរទឹករលកបោកពារច្រាំងលាន់ផាប់ៗ មិនយូរប៉ុន្មានក៏លេចឮស្នូរខ្ទក់ៗ យើងនឹងសង្កេតទៅឃើញរង្វង់ទឹកញែកពេញខាង ហើយស្រមោលខ្មៅទាំងនោះក៏បង្ហាញរូបរាងច្បាស់ឡើង ។ គឺជាទូកមួយក្រុម ដែលផ្ទុកដោយកងកម្លាំងប្រដាប់អាវុធ ប្រហែលមួយកងអនុសេនាធំ ។

បន្តិចក្រោយមកទូកទាំងនោះចូលបុកច្រាំងផាបន្តបន្ទាប់ បណ្ដា យុទ្ធជនក៏នាំគ្នាក្រោកឡើងលើកជាឡប់ពាក់លើខ្លួន ចាប់កាន់អាវុធគ្រប់ដៃ ហើយគោរពលាអ្នកម្ចាស់ទូកឡើងចេញដំណើរទៅ ។ រយៈបន្ទាប់មក សភាពស្ងប់ស្ងាត់នៃរាត្រីកាលចាប់គ្របដណ្ដប់លើច្រាំងមេគុងទាំងមូល ។ គេឮសូរតែសំឡេងបក្សីរាត្រីចរយំគុក ៗ ! នៅឯណោះមួយឯណោះមួយ ហើយនៅទីវាលនិងក្នុងព្រៃនាមឯនាយថ្មល់ជាតិមានឮសូរផ្គើចចកលូ ធ្វើឲ្យព្រឺក្បាល ។

អ្នកទូកមួយចំនួន ដែលបានចាប់អារម្មណ៍ទៅលើសភាពការណ៍គ្រោះអាសន្ន ឬ ចៃដន្យត្រូវកើតឡើង ក៏ចាប់ខ្សឹបខ្សាវផាក់គ្នា :

- នែបងប្អូន កងទ័ពរណសិរ្សបានចេញផុតអស់ហើយ យើងប្រញាប់នាំគ្នាវិលទៅវិញ !

- មែនហើយ (បុរសម្នាក់ឆ្លងសំដី) យើងសំងំនៅទីនេះមិនបានទេ !.. ឮសំឡេងសត្វយំឆ្លងឆ្លើយគ្នាកាន់តែជិតមក ៗ នៅក្បែរសមរភូមិអញ្ចឹង តាមខ្ញុំធ្លាប់ឮមិត្តយុទ្ធជនបដិវត្តយើងនិយាយថា មិនមែនជាសត្វា តចររកស៊ីធម្មតាទេ . . . .

- តើជាអ្វីទៅ បើមិនសត្វ ? (បុរសម្នាក់ទៀតសួរបញ្ជាក់)

- គឺជាខ្មាំងក្លែងភេទ ក្លែងសំឡេង ដើរស៊ើបការណ៍ . . .

- អ៊ើ . . . និយាយអញ្ចឹង ( អ្នកទូកម្នាក់ទៀតឲ្យយោបល់) ម៉្យលមិញនេះ តាមបងប្អូនប្រជាជនដើររកស៊ីបានផ្ដល់ដំណឹងថា មានពួកទាហានរដ្ឋការមួយកងអនុសេនាធំ បានមកបោះទីតាំងនៅឈរជើងនៅភូមិសក្ដិពីរ (១) ។

- ហ៎ាក ! ភូមិសក្ដិពីរនៅមិនឆ្ងាយពីកន្លែងចតនេះប៉ុន្មានទេ ! .: មិនស្រួលទេបងប្អូន យើងនាំគ្នាដកខ្លួនទៅវិញ !

- មែនហើយ ! តោះ ! ចេញដំណើរទៅ ! . . .

ខណៈនោះ អ្នកទូកដែលមានស្មារតីប្រុងប្រយ័ត្នបានម្ចាស់ការរៀង ៗ ខ្លួន ចេញដំណើរវិលទៅវិញយ៉ាងប្រញាប់ប្រញាលជាទីបំផុត ។ ដោយឡែកនៅសល់តែម្ចាស់ទូកមួយប៉ុណ្ណោះ ដែលកំពុងរៀបចំឥវ៉ាន់ក្នុងទូករបស់ខ្លួនពុំទាន់ចេញដំណើរ ។ ពេលគេទៅឃ្លាតឆ្ងាយមិនឃើញទូកនេះចេញ ទើបគេស្រែកតៀវថា :

- មក ! ល្បឿនភ្លូតអីយ ! នៅរៀបចំអីទៀត ចេញដំណើរមក ពួកយើងទៅអស់ហើយណា៎ !

ពូភួន ជាបុរស ឋិតនៅក្នុងវ័យប្រមាណហាសិបឆ្នាំ គាត់អន់ត្រចៀកបន្តិច ក្ដាប់មិនបានពីសភាពការណ៍ដែលអ្នកទាំងអស់លើកឡើងពិភាក្សាគ្នានោះទេ ។ គាត់គិតថា ដំណើររបស់គាត់ដូចជាដំណើរដែលគាត់ធ្លាប់ដើររកស៊ីរាល់ថ្ងៃ យ៉ាងដូច្នោះឯង ។ គាត់នៅតែរៀបចំឥវ៉ាន់ក្នុងទូកមិនឈប់ដៃ ។ ពេលនោះ កូនស្រីរបស់គាត់ក៏ផាស់សតិឡើង :

(១) ឈ្មោះអតីតភូមិមួយនៅតាមផ្លូវជាតិលេខ ១ ជាប់ព្រំឃុំបន្ទាយដែក ។

- ពុក ! ពុកនៅរៀបចំរបស់របរក្នុងទូកនេះដល់ណាទៀត គេចោលយើងអស់ហើយ !

- ហ៊ាក ថាម៉េច ? ( ពូភួនងាកមកបញ្ជាក់ ) ។

- គេរត់ចោលយើងអស់ហើយ !

គេទៅណា ទៅចុះកូន យើងចេញពីនេះទៅលក់បន្លែនៅចំណតផ្សារភូមិសក្តិពីរតែម្តង !

- អ៊ើ ! ទៅមិនទាន់បានទេពុក នៅយប់ណាស់ !

- ខ្លាចអីកូន រាល់ដងយើងទម្លាប់ចេញមករកស៊ីតែយប់ៗ អញ្ចឹងទេតើ ។

ចាស់ពិតមែន ! ប៉ុន្តែឥឡូវនេះយើងដើរយប់មិនបានទេ ព្រោះខ្ញុំឮគេនិយាយគ្នាអម្បាញ់មិញថា ពួកទាហានរដ្ឋការចូលមកនៅភូមិសក្តិពីរ ប្រយ័ត្នចូលទៅខុសពេលវេលាពួកវាចាប់យាត់យើងណ៎ាពុក !

- ពុកថា ជិតភ្លឺហើយ !

- ទេ ! នៅមិនទាន់ភ្លឺទេ យើងថយទៅវិញសិន !

- ពុកយល់ព្រម ... ឯណាពួកគេទៅដល់ណាហើយ ?

- គេទៅជិតពាក់កណ្តាលទន្លេទៅហើយ ។

- ហ៊ឺ ... ស្រេចហើយវី អ្នកទាំងអស់នេះគ្រាន់តែថាទៅ រត់ចោលគ្នាតែម្តង !



ពូភួននិយាយរួច ចាប់ស្រាយខ្សែហើយច្រានទូកចេញពីច្រាំង តែលំដាប់នោះស្រាប់តែមានស្នូរស្បែកជើងលាន់ព្រឹបៗ រត់ប្រសប់មកពីក្រោយខ្នង និងមានភ្លើងពិលបញ្ចាំងមកចំទូករបស់គាត់ ។ ពេលនោះក៏មានសំឡេងមនុស្សស្រែកសង្ឃ្លុកឡើង :

- ឈប់សិន ! អា អ្នកទូកឈប់ !

ពូភួននិងកូនស្រីគាត់ ងាកចោលខ្សែភ្នែកទៅ ឃើញទាហានមួយក្រុមចេញមកឈរច្រងច្រាងនៅលើមាត់ច្រាំង ។ ពួកវាសម្លឹងទៅឃើញទូកឯទៀតដែលចេញទៅឆ្ងាយហើយក៏ស្រែកហៅ :

- ពួកអ្នកទូកទាំងអស់ ឈប់សិន ឈប់ ! ... ( ទាហាននេះងាកនិយាយរកគ្នាវា ) .. ហ៊ឺ មកខកពេលបន្តិច ឥឡូវពួកទូកទាំងអស់នោះមិនព្រមឈប់ទេ ធ្វើយ៉ាងម៉េចទៅពួកយើង ?

ពលបាលឯកម្នាក់ស្ទុះចូលមកបញ្ជា :

- ពួកអាឯងនៅចាំអីទៀត បើពួកវាមិនព្រមឈប់ ម៉េចក៏មិនប្រើគ្រាប់សំណរដេញតាមវាទៅ !

ផុតសម្តីបញ្ជានេះ ស្នូរគ្រាប់កាំភ្លើងក៏ផ្ទុះឡើងប៉ុង ! ប៉ុង ៗ ! គ្រាប់ភ្លើងហោះ ចេវ ! ចេវ ! នៅពីលើក្បាលពូភួន ។ គាត់ប្រញាប់ទាញកូនក្រោំ ក្រាបផ្ងាប់នៅបាតទូកហើយខំលើកដៃសំពះសំរូងសុំសេចក្តីសុខវៀរចាកការគ្រោះថ្នាក់។ ពួកទាហានរដ្ឋការបាញ់កាំភ្លើង

អស់មួយសន្ទុះ ប៉ុន្តែគ្មានបានលទ្ធផលអ្វីសោះ ។ ទីបំផុតមេក្រុមរាក៏ឲ្យផ្អាកការផ្ទុះអាវុធនោះទៅវិញ ។

ពលបាលឯកនោះ ចុចពិលបំភ្លឺមើលទូកពួកភ្នួនព្រមទាំងបោះសម្តីសំឡុតថា :

– នែ៎ ! អាតាប៉ិម្ចាស់ទូកមួយនេះ នៅក្រោមស្ពន់ជាន់អី ម៉េចមិនក្រោកឡើង !

ពួកភ្នួនងើបមុខឡើង លើកដៃសំពះគេ ព្រមជាមួយសម្តីពោលឡើងញ័រប៉ិប៉ុបប៉ិប៉ុប :

– បាទលោក ... លោក ...

– នៅលោក ។ ដល់ណាទៀត ម៉េចមិននាំគ្នាឡើងគោកមកអញបាញ់បណ្តោតទឹកឥឡូវហ្នឹង !

ស្ថិតក្រោមអំណាចអាជ្ញាសឹកដ៏តឹងរឹង ពួកភ្នួនគ្មានមធ្យោបាយណាអាចគេចវេះបាន ត្រូវបង្ខំចិត្តឡើងមកលន់តួពួកគេ ។ ពលបាលឯកបញ្ចាំងភ្លើងពិលមើលមុខអ្នកទាំងពីរ ហើយក៏លាន់មាត់ :

– អ៊ូ ... ម្នាក់នេះជានារីទេហ្ន៎ះ ?

– បាទ ទានប្រោស កូនស្រីរបស់ខ្ញុំ !

– អី ... ពួឯងនិងកូន នាំគ្នាទៅណាមកណា បានជាចូលបកដល់កន្លែងនេះទាំងយប់អញ្ចឹង ?

– បាទ ! ខ្ញុំបាទជាប្រជាជន អ្នករកស៊ីលក់ផ្សារបន្លែបង្កា ...

– ប្រជាជនអ៊ើះ ! ? ( ពលបាលឯកបន្ទឺនូវពាក្យរួចចាប់ផ្ទុះសំណើច ) ។ ហាស ហាស ! . . . យើងកំពុងតែរកមុខពួកអា "ប្រជាជន" ប្រជាជនគឺ ពួកអារណសិរ្សរួបរួមជាតិ និង ពួកវៀតកុង ដែលកំពុងធ្វើសង្គ្រាមប្រឆាំងអ្នករដ្ឋការយើង !

– បាទទេ ទានប្រោស ! ខ្ញុំបាទនិងកូនខ្ញុំ ជាមនុស្សសាមញ្ញស្លូតត្រង់គ្មានដែលធ្វើអ្វីទេ !

– ចុះ ពួកអ្នកទូកដែលគេកខ្ចួនទៅបាត់អស់នោះ គេជាស្អីដែរ ?

– បាទ ខ្ញុំបាទមិនដឹងដែរ ខ្ញុំមកដល់ទីនេះតែពីរនាក់ឪពុកកូនប៉ុណ្ណោះ ។

– កុំកុហក ! ពួឯងពិតជាបានធ្វើសកម្មភាពអ្វីមួយ បានជាហ៊ានធ្វើដំណើរមកទាំងយប់ថ្ងៃនេះ ។

ពលបាលឯកងាកទៅបញ្ជាទាហាន :

– ទាហាន ! ចាប់ចងអាតាប៉ិនេះ និងកូនរបស់វាបណ្តើរទៅកាន់កន្លែងរបស់យើង ! . . . ពួកអាឯងមួយចំនួនទៀត ត្រូវនាំគ្នាចុះទូកនាំយកទៅពិនិត្យឆែកឆេរ រួចហើយធ្វើរ៉ាប់ពរជូនសែហ្វប៉ុស្តិ៍ជាបន្ទាន់ ស្តាប់បានទេ

– បាទទាន ទទួលបញ្ជា ។

* * *

មិនយូរប៉ុន្មាន កាលដែលពួកទាហានរដ្ឋការបណ្ដើរពូភួននិងកូនស្រីគាត់ចូលទៅដល់ភូមិសក្ដិពីរ ផ្ទៃមេឃចាប់ប្រែពណ៌សបំព្រាង ៗ ឡើង ។ គេបានយកជនទាំងពីរនាក់នេះ ទៅចងទុកនៅក្រោមដើមស្វាយមួយដើម ហើយចាត់គ្នាយាមកាមដោយប្រុងប្រយ័ត្ន ។

ភ្លឺឡើង យើងឃើញពូភួនត្រូវគេចងភ្ជាប់ទៅនឹងបង្គោលឫស្សីមួយ ឯកូនក្រមុំរបស់គាត់គេបានស្រាយចំណងចេញ តែក៏ស្ថិតនៅក្នុងរង្វង់ឃុំឃាំងទីនោះដែរ ។ ពូភួន និងកូនស្រីខំសម្លឹងមើលមុខគ្នាភ្លឹះ ។ មិនហ៊ាននិយាយស្ដីអ្វីឡើយ ព្រោះពួកទាហានរដ្ឋការកំពុងតែឃ្លាំចាំមើលនិងចាប់ខ្វាយលើអាកប្បកិរិយា ឬ ចំណុចផ្សេង ៗ របស់អ្នកទាំងពីរ ។ ទោះបីពូមានដៃត្រូវជាប់ចំណង ប៉ុន្ដែគាត់នៅតែរក្សាទឹកមុខមាំ បង្ហាញនូវភាពរឹងប៉ឹងមួយក៏រឹតឡើងវិញ ជាការជំនះចំពោះអំពើអយុត្តិធម៌ផង និងកុំឲ្យកូនស្រីមានការតក់ស្លុតផង ។

ក្នុងរយៈដែលគាត់ត្រូវទាហានចាប់ខ្លួនបានយកមកចងទុកនៅទីនេះ ពូភួនបានគូសវាសក្នុងគំនិតគិតឃើញរួចជាស្រេចហើយថា ពួកគេនឹងធ្វើទារុណកម្មលើរូបកាយគាត់ និងកូនស្រី ដើម្បីសួរយកចម្លើយពីសកម្មភាពតស៊ូបដិវត្តប្រឆាំងនឹងពួកគេ។ ជាការពិតណាស់គាត់ជាប្រជាជនចំរើនជឿនលឿនម្នាក់ ដែលបានចូលរួមចំណែកក្នុងចលនាតស៊ូរំដោះជាតិ។ ព្រឹត្តិការណ៍កន្លងមក គាត់ជាប្រជាជននៅភូមិកោះកែរគាត់តែងបានចេញទៅរកស៊ីដោះដូរស្រូវអង្ករពីតំបន់រំដោះយកមកចិញ្ចឹមជីវិត ។



គាត់បានទំនាក់ទំនងជាមួយរដ្ឋអំណាចនៅតំបន់រំដោះ ហើយស្ម័គ្រចិត្តចូលរួមចំណែកធ្វើសង្គ្រាមរំដោះជាតិ ។ គាត់បានជួយដឹកជញ្ជូនស្បៀងអាហារ គ្រាប់រំសេវនិងចម្លងកងទ័ពរណសិរ្សមកកាន់សមរភូមិជាញឹកញាប់ ។ ស្នាដៃនេះត្រូវបានអង្គការបដិវត្តន៍មូលដ្ឋានទទួលស្គាល់យល់ព្រមឲ្យគាត់មានសិទ្ធិចេញចូលពីតំបន់រំដោះមកតំបន់រដ្ឋការ ឃុំត្រង់បានជាធម្មតា ដោយប្រកបមុខរបរជាអ្នករកស៊ីលក់ដូរបន្លែបង្កា ។

ប៉ុន្ដែពេលនេះ ដែលដំណើររបស់គាត់ត្រូវជួបឧបសគ្គខ្លាំងចាប់ខ្លួនបាន ពូភួនគិតថា ត្រូវរក្សាលក្ខការណ៍សម្ងាត់ជូនបដិវត្តន៍ ឲ្យបានដាច់ខាត ។ អ្នកបដិវត្ត និងពួកទាហានរដ្ឋការហ្វាស៊ីស្តជាសត្រូវបដិវត្តស្លាប់ រស់ ទោះក្នុងកាលៈទេសៈណាក៏ដោយ មិនអាចចុះញមចំពោះមុខសត្រូវឡើយ ។ ស្មារតីរបស់ពួកវា គឺ ឫសគល់នៃរបបមូលធននិយម មានគំនិតប្រតិកិរិយាផុតលេខ ជាកិច្ចការប្រឆាំងចំពោះបដិវត្តន៍ និងប៉ុនប៉ងរំលាយការតស៊ូបដិវត្ត ។

ថ្ងៃរះផុតចុងឈើ មេចទាហានម្នាក់មាឌធំដំបង កាន់មោងក្ដោមមួយ ដើរចូលមកឈរនៅចំពោះមុខពូភួនក្នុងរយៈជិត ។ កូនស្រីរបស់គាត់ឃើញទាហានវេះ ចាប់ប្រែទឹកមុខស្លក់ស្លាំងមួយរំពេច ។

ជននោះបោះសម្ដីទៅកាន់អ្នកយាម :

- នែ៎ អាគុក ! ឯងយកនាងក្រមុំនេះចេញពីមុខពីមាត់អញ ទុកឱកាសឲ្យអញបានសួរសុខទុក្ខពុកវាបានសមរម្យបន្តិច !

- បាទបាទ . . . ( នាយគុកស្ទុះភ្លែតគះយុវតីចេញ ហើយឈររវៃនឹងកាំភ្លើងអែរ ១៥ )

ជនសួរចម្លើយចូលទៅចាប់ភ្ជួយចង្កាសម្លឹងមុខពូភូទដែលចងភ្ជាប់នឹងបង្គោល ផះសម្តីធំៗដាក់គាត់ :

- ហែ៎ក ! មើលមុខយើងឲ្យច្បាស់ រួចនិយាយប្រាប់យើងឲ្យត្រង់ៗ មក ពួកយប់មិញនេះពិតជាបានដឹកជញ្ជូនគ្រឿងទ័ពរណសិរ្សនិងពួកវៀតកុងមកកាន់ដីស្រុកលើកដែកនេះមែនហ៎ាក៏ ?

ពូភូទងើបសម្លឹងមុខទាហានសួរចម្លើយនេះមួយភ្លែត គាត់លេបទឹកមាត់ក្អឹករួចនិយាយតប :

- ខ្ញុំបានជំរាបការពិតប្រាប់អស់លោករួចមកហើយ ថាខ្ញុំជាពលរដ្ឋស្លូតត្រង់មានមុខរបររកស៊ីលក់ដូរបន្លែបង្កា ហើយមានទម្លាប់ធ្វើដំណើរមកកាន់ទីនេះពេលយប់អញ្ចឹង ជាក់ស្តែងពួកអស់លោកបានពិនិត្យឃើញអស់ហើយ នៅក្នុងទូករបស់ខ្ញុំមានចេកអំពៅនិងបន្លែផ្សេងៗទៀត . . .

- នែ៎ ! ស្តាប់សម្តីខ្ញុំឲ្យបាន ( ទាហានពោលកាត់ ) យើងមិនសួរពីមុខរបរឯងទេ យើងសួរពីពួកខ្មាំង !

- ខ្ញុំបាទ ពុំបានដឹង និងពុំបានធ្វើសកម្មភាពបំរើខ្មាំងទេ !



- មិនដឹងហ៎ះ ភស្តុតាងមានច្បាស់ក្រឡែត យើងបានទៅទាន់ឃើញពួកឯងគេចខ្លួនទៅកណ្តាលទន្លេ បើយើងជាមនុស្សសុចរិតត្រឹមត្រូវមែន មិនបាច់រត់ទេ !

- ខ្ញុំបាទមិនយល់ដែរ បងប្អូនទាំងអស់នោះមានដំណើរដោយឡែកពីខ្ញុំ ។

- កុំនិយាយដោះសា

- ខ្ញុំនិយាយស្មោះត្រង់ណ៎ាលោក

- ហ៊ុះ ! ស្មោះត្រង់ហ៎ះ ! ស្មោះត្រង់នឹងពួករណសិរ្សវៀតកុងនោះឬ ? ឆ្លើយប្រាប់មក ! ពួកឯងបញ្ជូនខ្មាំងចូលមកវាយពួកយើងប៉ុន្មានលើកហើយ ? ឥឡូវនេះវាយកប៉ុន្មានទៀត ? ទិសដៅរបស់ពួកវាប្រុងវាយនៅកន្លែងណាខ្លះ ?

- ខ្ញុំបាទ គ្មានដឹងសោះ !

- យើស ! ចំពាក់ក្បាលរឹងតែម្តងហើយវ៊ី អាពួកអ្នកតស៊ូបដិវត្តស្អីនោះ បានបំពាក់ជំហរស្មារតីឲ្យគាត់ឯងចេះលាក់ការណ៍ដល់ជីវិតខ្ពស់បំផុត ! ហើយដាច់ខាតបំផុត !... ឯងគ្រាន់បើចាំទទួលរង្វាន់ទៅ !

ទាហានប្រតិកិរិយា ក្តាប់មាត់លើករំពាត់ក្តៅវាយវ៉ាត់អស់ទំហឹងដៃទៅលើរាងកាយពូភូទជាប់ៗ ព្រមជាមួយនេះវាក៏ស្រែកបន្ទរថា : " ស្លាប់ទៅ ! ... ស្លាប់ទៅអាកញ្ចាស់ ! ... " រាងកាយពូភូទក៏រើករមួលដូចជាអន្ទង់ត្រូវគេគាបនឹងដំបងឆ្កើរលើភ្លើង ។

គាត់ខំខាំមាត់សង្កត់ចិត្តមិនទម្លាយនូវសម្រែកឈឺចាប់ នាំឱ្យកូនស្រីស្លុងស្មារតីឡើយ ។ ប៉ុន្តែយុវតីក្រឡេកមកឃើញឪពុកត្រូវគេធ្វើទារុណកម្មបែបនេះ នាងអាណិតស្ទើរតែខ្លោចថ្លើមប្រមាត់ ។ នាងលោតអន្ទះសាប្រុងស្ទុះមកជួយ តែត្រូវទាហានយាមការពារច្រានដួលច្រងាប់ច្រងិល ។ នាងខំងើបឡើង ក្រឡេកទៅឃើញឪពុកទន់ខ្លួនស្រុតចុះ នាងទប់ចិត្ត លែងបានក៏ស្រែកយំងោងឡើង ។

ពលបាលសួរចម្លើយមិនបានយកចិត្តទុកដាក់ នឹងការយំសោកនៃយុវតីនេះទេ វាចូលទៅចាប់សក់ក្បាលពុកភួនងើយឡើងម្តងទៀតយកក្ត នគារគោះចំថ្ពាសបីបួនប៉ុក បីដូចជាវាគោះត្រឡោកលេងព្រមទាំងពោលសម្តីគំរាមថា :

– ម៉េច អាឯងមិនទាន់ចង់ងាប់ទេ មិនថាអញ្ចឹង ! ឥឡូវឆ្លើយម៉ោ ! កុំឱ្យឈឺខ្លួនតទៅទៀត ! ឯងនាំខ្មាំងចូលមកក្នុងភូមិសាស្ត្រនេះមែន ឬ មិនមែន ? ពួកវាមានគ្នាប៉ុន្មានក្បាល ?

ពុកភួនបើកភ្នែក ស្រែកដាក់វា :

– អញមិនដឹង ! អាស្អួងសួរបង្កាច់ក្នុងរឿងដែលអញមិនបានប្រព្រឹត្ត តើអញបានអីឆ្លើយ ! ?

– មិនឆ្លើយហ៎ះ ! បានសេចក្តីថា អាកញ្ចាស់ឯងចង់ប្រថុយស្បែកនៅចំពោះមុខអាវុធ !



– កុំព្រៃផ្សៃពេក អាទាហានហ្វាស៊ីស !

– ហ៎ា ហ៎ាស !

ឧទានតែប៉ុណ្ណោះ ទាហានយង់ឃ្នងស្ទុះទៅធាក់យ៉ាងតំណាំចំដើមទ្រូងពុកភួន ហើយចាប់វាយវាត់ហូតដល់គាត់សន្លប់បាត់មាត់សូន្យ ។ វាឈរសម្លឹងបញ្ចេញគ្រាប់ភ្នែកក្រហមងាំងដូចរងើករភ្លើង បន្តិចមកទើបងាកទៅរកអ្នកយាម :

– អាគុក ! យកទឹកមួយត្រឡោកមកផះមុខវា កាលណាវាដឹងខ្លួនអញវាយសួរចម្លើយទៀត ! ។

– បាទទាន ! . . .

ខណៈនោះ មានស្នូរកញ្ចែបន្លឺឡើងនៅឯនាយ ពួកទាហាននាំគ្នារត់ប្រសេចប្រសាចទៅកាន់កន្លែងបញ្ជាការ ឯពលបាលសួរចម្លើយនេះក៏ផ្អាកការធ្វើទារុណកម្ម រង់ចាំស្តាប់សភាពការណ៍សិនដែរ ។

*

* *

រថយន្តហ្ស៊ីប មួយគ្រឿងទើបបានបរចូលមកឈប់នៅក្នុងភូមិសក្តិៈពីរ ។ លំដាប់នោះគេឃើញទាហានបួននាក់ ប្រដាប់ដោយអាវុធគ្រប់ដៃ លោតចុះពីរថយន្តព្រឹប ៗ ! មកឈរចាំការពារមនុស្សម្នាក់ដែលកំពុងចាកចុះមកក្រោយគេនោះ ។ ជនដ៏មានបណ្តាសក្តិនេះគឺលោកអនុសេនីយឯកអ៊ុយ ផែល ។

លោកផែលស្ថិតនៅក្នុងវ័យប្រហែលជិតហាសិបឆ្នាំ , គាត់មានសក់រួញ មុខរាហ៍ មានឧទាបកន្ទ្រល ប្រដាប់ដោយសម្លៀកបំពាក់ក្នុងឯកសណ្ឋានយោធា និងមានសក្តិស្លឹកស្កះនៅលើស្មា ។ អត្តចរិតរបស់គាត់ បង្ហាញនូវភាពជាអ្នកលោភអំណាច និងវាយឫកក្រអឺតក្រអោង។

លោកផែលចាប់បោះជំហានមួយៗទៅកាន់ទីខាងមុខ ដែលមានទាហានមួយកងអនុសេនាតូច កំពុងរត់មកតម្រង់ជួរចាំគំនាប់គាប់ផាដោយឈរត្រង់ជើងតឹង ! ។ ពេលដែលពួកទាហានទាំងនោះ ធ្វើការកិច្ចរួចហើយ លោកផែលចាប់មានប្រសាសន៍ទៅកាន់បញ្ជាការម្នាក់ថា :

- បាន ! . . . ល្អហើយសែហ្វ ឆាត ! . . . ចាត់ការឱ្យពួកទាហានទាំងនេះទៅកាន់កន្លែងត្រៀមចុះ !

សែហ្វឆាតគោរពបញ្ជា រួចងាកទៅដាក់ឱវាទដល់បណ្តាកូនទាហានឱ្យចេញទៅការពារខាងក្រៅយ៉ាងម៉ឺងម៉ាត់ ។ បន្ទាប់មក សែហ្វឆាត ក៏អញ្ជើញលោកផែលទៅសំរាកនៅលើគ្រែមួយ ដែលស្ថិតនៅក្រោមម្លប់ស្វាយមួយដើមធំ ។

ក្រោយពីសម្រួលឥរិយាបថ និងហូបទឹកជក់បារីមក លោកផែលចាប់ធ្វើការជាមួយសែហ្វឆាតភ្លាម :

- សែហ្វឆាត ថ្ងៃនេះមានព្រឹត្តិការណ៍កើតឡើងគួរឱ្យកត់សំគាល់ទេ?



សែហ្វ ឆាតគោរពរួចចាប់រាយការណ៍ :

- តេជគុណ ! ខ្ញុំបាទសូមរាយការណ៍ជូន យប់មិញនេះនៅវេលាម៉ោងបួនទៀបភ្លឺ ពួកយើងខ្ញុំបានដើរប្រតិបត្តិការនៅតាមមាត់ទន្លេ បានប្រទះឃើញពួកទូកមួយក្រុម ឆ្លងពីត្រើយនាយមកនៅពេលដែលយើងព័ទ្ធហៅពួកវា ៗ ក៏ប្រាសទៅក្នុងទន្លេអស់ទៅ នៅសល់តែទូកមួយប៉ុណ្ណោះដែលយើងចាប់បានទាំងមនុស្សពីរនាក់ផងបាទប្រោស !

- អ៊ំា !( លោក ផែលបើកភ្នែកធំៗ ដោយចាប់អារម្មណ៍ ; សែហ្វឆាតឯងអាចសន្និដ្ឋានបានថា ពួកទាំងនោះជាអ្វីទេ ?

- បានទាន តាមការពិនិត្យនិងវាយតម្លៃរបស់យើងខ្ញុំ ពួកទូកដែលឆ្លងមកថ្មើរនោះ មិនមែនជាប្រជាពលរដ្ឋរកស៊ីធម្មតាទេ វាពិតជាពួកខ្មាំង ឬ កងដឹកជញ្ជូនរបស់ខ្មាំង !

លោកផែលតំឡើងទឹកមុខមាំ ក្រោកឡើង ខាំកន្ទុយបារីរួចក្រវាត់ចោលដើរក្រញាត់ដៃពីរ . បែរទៅមុខសែហ្វឆាត :

- ជាការពិតណាស់ហើយ ! តាមពត៌មានពីប្រភពច្បាស់ការណ៍បានឱ្យដឹងថា ពួកខ្មែរក្រហមនិងវៀតកុង មានគំរោងការវាយបន្ទាយគគីធំ និងបណ្តាទីតាំងរបស់យើងនៅតាមបណ្តោយផ្លូវជាតិលេខ១នេះ ! ដូច្នេះពួកទូកទាំងនោះ បើមិនមែនជាកងកម្លាំងរបស់ខ្មាំងទេ ក៏ជាកងដឹកជញ្ជូនស្បៀងអាហារ និងគ្រាប់រំសេវមកផ្តល់ឱ្យពួកវា ដែលនៅធ្វើសកម្មភាពក្នុងស្រុកលើកដែកនេះ !

_ បាទ ទានប្រោស ! ឥឡូវ ចំពោះជនពីរនាក់ជាឪពុកកូន ដែលយើងខ្ញុំចាប់បាននៅលើទូកមួយនោះ កំពុងស្ថិតនៅក្នុងការឃុំឃាំង និង កំពុងសួរយកចម្លើយ . . .

លោកផែលងក់ក្បាលមួយ ៗ :

អឺ! . . សែហ្វឆាតឯង សាកសួរវាបានការយ៉ាងម៉េចខ្លះហើយ?

_ មិនទាន់បានលទ្ធផលអ្វីសោះទានប្រោស ! ជនពីរនាក់នោះ ក្បាលរឹងបំផុតមិនព្រមនិយាយប្រាប់កិច្ចការអ្វីមួយពីពួកខ្មាំង . . .

លោកផែល ក្តាប់កាន់មោងក្តគោគោះនឹងបាតដៃផាញីកញាប់ព្រម ទាំងសួរដេញដោល :

ហ៊ឹះ ! . . . បើវាមិនព្រមប្រាប់ពីសកម្មភាពរបស់ខ្មាំងទេ ម៉េច សែហ្វឆាតឯងមិនប្រើវិធានការយោធាឱ្យក្តៅបន្តិច ?

_ ទានប្រោស ! ពួកយើងខ្ញុំបានប្រើធមិក្តៅទៅលើបុរសម្ចាស់ ទូកនោះស្ទើរតែឆ្អែតដៃទៅហើយទាន តែនៅតែគ្មានបានការអ្វីសោះ

_ កំសាក ! ( លោកផែលសង្ស្រកដោយសម្តីធំ ៗ ) រឿង ប៉ុណ្ណឹង បើលោកឯងធ្វើការមិនកើត មិនមែនមានឈ្មោះថាជាទាហាន រដ្ឋការទេ ! ឥឡូវវាទាំងនោះនៅឯណា យកមកឱ្យយើងភ្លាម !

សែហ្វឆាតគោរពហើយចេញទៅបញ្ជាកូនទាហានរបស់ខ្លួនឱ្យទៅ យកជនជាប់ពិរុទ្ធ មកបង្ហាញចៅហ្វាយនាយ ។ ពេលដែលឃើញ បុរសម្ចាស់ទូក និងកូនក្រមុំរបស់គាត់មកស្ថិតនៅចំពោះមុខ លោក



ផែលដែលពីមុនទឹកមុខក្រមួរ ឥឡូវប្រែស្រាយមុខចាប់ញញឹមញញែម វិញ :

" អ្ហ៎ា . . . នាងក្រមុំម្នាក់នេះស្អាតណាស់តើ ? . . ."

( លោកផែលលាន់មាត់តិច ៗ ) ។

អនុសេនីយ៍ឯកសក់ល្បាយអាចម៍ខ្លា បោះជំហានចូលទៅជិត បុរសម្ចាស់ទូកលើកដៃពាល់ស្មាបង្ហាញនូវភាពគាត់ជាមនុស្សចិត្តល្អផា :

_ លោកពូ . . . លោកពូឈ្មោះអី ?

បុរសចំណាស់លើកដៃសំពះព្រមទាំងបន្ទឹឡើងញ័រគគាក់គគុប :

_ បាទ ! តេជគុណ ខ្ញុំបាទឈ្មោះភួន ។

_ ចុះ នាងខាងណេះជាកូនលោកពូឬ នាងឈ្មោះអីដែរ ?

_ បាទ ! កូនរបស់ខ្ញុំ . . . ឈ្មោះសម្ផស្ស ។

_ ឱឈ្មោះសម្ផស្ស ! . . . ឈ្មោះពិរោះណាស់ សមនឹងរូប រាងដ៏ស្អាត !

លោកផែលពោលទាំងញញឹម ព្រមទាំងសម្លឹងមើលមុខសម្ផស្ស ផាញឹកញាប់ ។ គាត់ចាប់សួរ ពូភួនតទៅទៀត :

_ លោកពូ នៅភូមិណា ? ហើយអញ្ជើញមកទីនេះមានការអី?

_ បាទ ទានប្រោស ! ខ្ញុំបាទនៅភូមិកោះកែវ ខ្ញុំបាទនាំកូនមក ទីនេះដោយដឹកផលដំណាំមកលក់ដូរ . . .

_ ដឹកផលដំណាំមកលក់ដូរ ? មានអ្វីខ្លះ ?

HUN SEN LIBRARY

- បាទ មានចេកអំពៅនិងបន្លែបង្កា . .

- ចុះហេតុយ៉ាងម៉េច បានជាលោកពូ ធ្វើដំណើរមកទាំងយប់អញ្ចឹង ?

- ជំរាបប្រសាសន៍ អ្នកភូមិយើងខ្ញុំនៅត្រើយខាងណោះ តែងមានទម្លាប់ដឹកនាំផលដំណាំមកលក់ផ្សារនៅត្រើយខាងណេះរៀងរាល់ថ្ងៃ ការចេញដំណើរមកពីយប់លៃល្មមភ្លឺដល់ទីនេះប៉ុន្តែខ្ញុំបាទ មកម្តងនេះខុសពេលបន្តិច ... សូមទានអនុគ្រោះ ។

លោកផែលងក់ក្បាលមួយៗ ទំនងដូចជាគាត់មានការយោគយល់ :

- ខ្ញុំអាចជឿបានថា លោកពូមិនបានដឹងពីបញ្ញត្តិរបស់រដ្ឋការស្តីពីការហាមឃាត់អ្នកធ្វើដំណើរពេលយប់ បើសិនជាលោកពូបានដឹងហើយនៅបំពាននោះ គឺនឹងត្រូវព្រមានឬទទួលទោសដោយខានមិនបាន !

សូមទានអភ័យទោស ខ្ញុំបាទមិនដឹងទេ បើដឹងមិនធ្វើខុសច្បាប់ឡើយ !

- ខ្ញុំក៏យោគយល់លោកពូដែរ ខ្ញុំអាណិតលោកពូណាស់ ! និងស្តាយណាស់ដោយកូនទាហានរបស់ខ្ញុំ មិនបានគិតពិចារណា ទៅផារវាយធ្វើបាបលោកពូឲ្យបែកឈាម ហើមអស់ទាំងខ្លួនប្រាណ ... ។



- បាទតេជគុណ ទារុណកម្មនេះចាត់ទុកជាផាភ័ព្វវាសនាអាក្រក់របស់ខ្ញុំបាទ កើតឡើងដោយចៃដន្យទៅចុះ !... បើខ្ញុំបាទមិនមានការខុសឆ្គងនឹងច្បាប់ទេ ខ្ញុំបាទសូមលាតេជគុណទៅវិញ ។

លោកផែលញញឹម ដោយកែវភ្នែកភ្លឺ :

- បាទ ដូចខ្ញុំនិយាយអញ្ចឹង ខ្ញុំក៏មានការអនុគ្រោះចំពោះពូដែរ សុំពូអញ្ជើញទៅផ្ទះមើលថែទាំខ្លួនចុះ ! ប៉ុន្តែចំពោះកូនស្រីរបស់ពូ ខ្ញុំសុំទុកនៅទីនេះសិន !

សម្តីដ៏ផ្អែមល្ហែមប្រៀបបានទឹកឃ្មុំរបស់លោកផែល បានប្រែក្លាយទៅជាថ្នាំដ៏មានពិសពុលបំផុត នៅពេលដែលគាត់បន្លឺពាក្យប៉ុន្មានម៉ាត់ចុងក្រោយនេះ ។

- តេជគុណ យើងខ្ញុំទាំងពីរនាក់ជាឪពុក កូន មិនអាចទៅចោលគ្នាបានទេ បើតេជគុណអនុគ្រោះដោះលែង គឺលែងទាំងអស់គ្នា ទុកកូនស្រីខ្ញុំនៅទីនេះមិនកើតទេ !

- កូនស្រីរបស់ពូ មិនទាន់បានផ្តល់ពត៌មានឲ្យយើង !

- បាទ កូនខ្ញុំគ្មានពាក្យសម្តីអ្វីជំរាបលោក ក្រៅពីពាក្យដែលខ្ញុំបានជំរាបហើយនោះទេ !

- ហ៎ា ហ៎ាស ! . . ( លោកផែលសើចសប្បាយ ) យើងទុកនាងនៅបំរើយើងមួយយប់ពីរសិនណ៎ាពូ !

- ទេ ! ធ្វើអញ្ចឹងមិនកើតទេលោក ! ខ្ញុំសុខចិត្តឲ្យកូនទៅផ្ទះ ខ្ញុំនៅបំរើលោកប៉ុន្មានថ្ងៃក៏បានដែរ !

- នៅបានការអី ! . . . ហ៊ា ហ៊ាស ! ខ្ញុំត្រូវការតែសម្ផស្ស ប៉ុណ្ណោះ !

- ទេខ្ញុំ ខ្ញុំមិនយល់ព្រមនឹងបំណងរបស់លោកទេ !

លោកផែលតំឡើងមុខក្រញូវ និងចាប់បន្ទឺយ៉ាងតឹងរឹង :

- ហ៊ឺះ! ម៉េចខ្ញុំនិយាយនឹងពួកឯងស្តាប់មិនបានឬ ? សូមពួយល់ថា ការដោះលែងរបស់ខ្ញុំនេះ គឺជាគុណភាពមិមួយដ៏ខ្ពង់ខ្ពស់ណាស់ទៅហើយ! តាមពិត យើងយល់ស្រេចទៅហើយថា ពួកឯងជាខ្មែរក្រហម ឬខ្មែររយៈរបស់ខ្មាំងដែលនាំទ័ពមកវាយយើង ពួកឯងត្រូវមានទោសដោយជាប់គុកច្រវាក់ខានមិនបាន . . . យកល្អ បើយើងដោះលែងហើយត្រូវថយប្រញាប់ ទុកតែកូនស្រីមួយប៉ុណ្ណោះឲ្យយើង ។

- ទេ លោក ! លោកកុំធ្វើអញ្ចឹង !

- សែហ្វឆាត ! អូសក្បាលអាកញ្ចាស់នេះចេញ !

ខណៈនោះទាហានពីរនាក់ស្ទុះមកក្រៀកស្មាពូភូច ហើយអូសចេញទៅ ។ ពូភូចខំងាក់ដីក្រាញងាកមកមើលកូនក្រមុំរបស់ខ្លួនព្រមទាំងស្រែកឡើង :

" សម្ផស្ស កូនមាសឪពុក ! . . . "



សម្ផស្សខំរត់តាមឱបឪពុកជាប់ ហើយចាប់ទ្រហោយំ ។ ប៉ុន្តែលោកផែល ដែលកំពុងមានការស្រេកឃ្លានលំអនារីនេះ ក៏មិនសុខចិត្តឲ្យនាងក្រមុំស្ទុះរួចពីកណ្តាប់ដៃឡើយ ។ គាត់ស្រែកបញ្ជាកាប៉ូរ៉ាល់ម្នាក់ភ្លាម :

- អាសន ! នៅឈរធ្វើភ្លើអី ! ម៉េចក៏មិនទៅចាប់នារីនោះមកឲ្យអញ !

កាប៉ូរ៉ាល់សនជាមនុស្សជំនិតរបស់លោកផែល កាលឮសម្តីចៅហ្វាយនាយ ក៏ស្ទុះក្រទឹប្រទាទៅចាប់អូសនាងសម្ផស្សមកដាក់ឡាន ហើយគេទាំងអស់គ្នាក៏ស្ទុះឡើងរថយន្តនោះ បើកចេញទៅយ៉ាងប្រញឹបប្រញាប់ប្រញ៉ៀបបីដូចពួកចោរប្លន់ ឬ ដូចសត្វខ្លែងឆាបកូនមាន់អញ្ចឹង ។

*

* *

# ២

## រាត្រីអបលក្ខណ៍

រថយន្តរត់ចូលមកដល់សង្កាត់ជាយក្រុង លោកផែលដែលមានសេចក្ដីប៉ិនប៉ងប្រាថ្នាឋាកនាងសម្ផស្ស ទៅបំរើខាងផ្លូវកាមារម្មណ៍របស់ខ្លួនក៏បានគូសវាសនៅក្នុងគំនិតទុកហើយជាស្រេច ។ គាត់ចាប់ផ្ដើមនិនខ្សឹបខ្សៀវតិច ៗ ដាក់ត្រចៀកកាប៊ូរ៉ាល់សន :

" សន ! សនឯងយកនាងក្រមុំនេះ ទៅលាក់ទុកនៅផ្ទះរបស់ឯងឯភូមិច្បារអំពៅនេះសិនណ៎ា បើយានិយាយប្រាប់ប្រពន្ធរបស់ឯងឲ្យស្រួលបួល ព្រមទាំងមើលផ្គត់ផ្គង់ថែរក្សាការពារនាងផង ! "

— តេជគុណ ( នាយសនសួរបញ្ជាក់ ) ... ម៉េចបានជាមិនយកអ្នកនាងនេះចូលទៅក្រុងតែម្ដង ?

— ឆ្កួត !.. ឲ្យអញយកទៅធ្វើម្ដេចកើត ដឹងទេ លោកស្រីរបស់អាងកំពុងតែតាមដានអញរាល់ថ្ងៃ ... ទុកនៅផ្ទះឯងនេះសិនហើយ !

— អញ្ចឹង តេជគុណអញ្ជើញទៅសំរាកនៅផ្ទះខ្ញុំក្នុងពេលនេះដែរឬ ?

— ទេ ! .. ដល់ម៉ោងហើយ ! .. អញមានការប្រញាប់ឡើងទៅប្រជុំ ... ចាំដល់ពេលយប់ឱកាសល្អ អញនឹងមកជួបនាង ។



— ហ៎ា ! តេជគុណគិតមកចាត់ការលើផ្ទះខ្ញុំ ... បែបមិនស្រួលទេឬ ទាន រីរលោកស្រីដឹង ? ...

— មិនអីទេ ! .. ផ្ទះរបស់ឯងនេះស្ងាត់ជាងទីណាៗ ទាំងអស់! លោកស្រីឯងមិនដែលមកទីនេះទេ តែដល់អញមកដេកនៅជាមួយនាង ឯងទាំងពីរនាក់ប្ដីប្រពន្ធនៅខាងក្រោមចាំការពារអញផង ម៉េចស្ដាប់បានទេ !

— បាទទាន ខ្ញុំនឹងរៀបជើងព្រលឲ្យស្អាតជូនតេជគុណ !

— ហ៎ា ហ៎ាស ! ... លោកផែលសើចលាក់ខ្លួនដោយរីកថ្ងើមប្រមាត់ ។

រថយន្តរត់បត់ចូលតាមផ្លូវមួយទៅក្នុងជម្រៅភូមិច្បារអំពៅ ។ ទៅដល់ពាក់កណ្ដាលភូមិ រថយន្តនោះក៏ឈប់ នាយសនងាកមកនិយាយប្រាប់នាងសម្ផស្សឲ្យចុះ រួចគេនាំនាងដើរទៅកាន់ផ្ទះកន្ទាំងមួយដែលស្ថិតនៅក្នុងព្រៃចេក ។

ឯលោកផែលក៏បញ្ជាឲ្យអ្នកបើកបររបស់គាត់បត់ឡានចេញមកវិញយ៉ាងប្រញាប់ វិស័យដូចជាពួកឈ្មួញរត់ពន្ធ ដែលខំគេចខ្លួនឲ្យផុតពីភ្នែកគយ ឬ ប៉ូលីសយ៉ាងដូច្នោះឯង ។

ថ្ងៃនោះ លោកផែលជាប់ប្រជុំនៅ " អគ្គសេនាធិការយោធពលខេមរភូមិន្ទ " តាំងពីព្រឹករហូតទាល់ល្ងាច ។ គាត់គិតថាចប់ការប្រជុំនោះ នឹងចេញទៅជួបនាងសម្ផស្សតាមការណាត់ពេលវេលាទុកជា

មួយនាយសន ។ ប៉ុន្តែកាលពេញមកដល់មាត់ទ្វាររបង ស្រាប់តែឃើញកូនប្រុសរបស់គាត់ឈ្មោះ ប៉ាកាណាមកបញ្ឈរម៉ូតូចាំហើយជាស្រេច ។

– អ្វី !.. អាប៉ាកាណា កូនឯងមកធ្វើអីនេះ ?

– បាទប៉ា ( យុវជនឆ្លើយ ) ម៉ាក់ឱ្យខ្ញុំមកតាមរកប៉ា . . .

– អុញ ! . . . អាកូនចំកួត ឯងម៉េចក៏ចាំដើរតាមរកអញមើលតែអញនេះកូនក្មេងមិនដឹងផ្ទះសម្បែងឬអី ?

– មិនអញ្ចឹងទេប៉ា តែម៉ាក់មិនសូវស្រួលខ្លួន ហើយប៉ាដើរចោលផ្ទះយូរពេក បានជាម៉ាក់ឱ្យខ្ញុំតាមរក !

– អាឆ្អែង ដឹងអញដើរធ្វើការទេ ?

– បាទ . . . បើប៉ាចប់ការងារហើយសូមអញ្ជើញទៅផ្ទះ ។

– ទៅ ! អញដឹងផ្ទះហើយ កុំចាំបាច់មកបណ្ដើរអញ ! . . .

លោកផែលពោលទាំងរអ៊ូរទាំ ហើយងាកទៅឡើងរថយន្តបញ្ឆេះចេញរឹងទៅ ។

ចូលដល់គេហស្ថាន លោកផែលឡើងទៅឃើញអ្នកស្រីជាភរិយាអង្គុយនៅសាឡុងបង្ហាញទឹកមុខស្មើ ។ គាត់បោះជំហានហួសចូលទៅបន្ទប់ ហើយដោះខោអាវក្រវ៉ាត់ព្រួសព្រួសរួចដើរចេញមកវិញទាំងមុខមិនរីកចេកមិនទុំ ។



– ម៉េចហ្នឹងលោក ? ( អ្នកស្រីបន្ទីវាចាសួរ ) មកពីមីស្បងនោះសមរភូមិទទួលបរាជ័យឬបានជាចូលមកដល់ផ្ទះបែបក្ដៅក្រហាយម្ល៉េះ?

លោកផែលដាក់បង្គុយលើសាឡុងទល់មុខភរិយា ចាប់ពោលឡើងយ៉ាងគំរោះគំរើយ :

– ម៉ាក់វា ! . . . ប្រើសម្ដីឱ្យល្អបន្តិច ។ បានហើយ ខ្ញុំមិនចង់ឮឯងនិយាយមកកាន់ខ្ញុំបែបនេះទេ !

– យ៉ាងម៉េច ពាក្យរបស់ខ្ញុំមានទាន់មានអ្វីជាការខុសឆ្គងគ្រាន់តែសួរពត៌មានលោកប៉ុណ្ណោះអីតើ ?

– មែនហើយ !.. ម៉ាក់វាឯងជាមេផ្ទះ តើត្រូវប្រើពាក្យសំដីយ៉ាងណាចំពោះស្វាមីដែលទើបវិលមកពីបេសកកម្ម ! . . .

– ខ្ញុំយល់ទុក្ខធុរៈនិងការហត់នឿយរបស់លោកណាស់ណា ខ្ញុំអាចធ្វើបានទាំងអស់ចំពោះតួនាទីខ្ញុំជាភរិយារបស់លោក ! . . . ក៏ប៉ុន្តែលោកក៏គួរយល់ពីតួនាទីស្វាមីចំពោះភរិយាផងដែរ លោកធ្វើដំណើរចេញទៅបាត់ ៗ ពីផ្ទះ លែងរវល់នឹកនាដល់គ្រួសារ . . . .

– ដឹងថាខ្ញុំជានាយទាហានរដ្ឋការជាប់មីស្បងទេ ! . ?(លោកផែលពោលកាត់ ) ។

ខ្ញុំយល់ហើយ ! មីស្បងរបស់លោកវាញឹកញាប់ពេកណាស់!. ប៉ុន្តែក្រោយពេលបេសកកម្ម លោកជាប់ . . . អីទៀត ? បានជាមិនសូវចូលផ្ទះ ! . . ខ្ញុំអាចដឹងបានណាលោក !

- ដឹងស្អី ? . . . តើបានអ្វីក្រៅពីកិច្ចការប្រទេសជាតិ ?

មិនបាច់លាក់បាំងនឹងខ្ញុំទេ!.. កន្លងមកខ្ញុំបានតាមដានដឹងអស់ហើយ លោកបានភូតភរខ្ញុំថាទៅមីស្សុងនៅសមរភូមិនេះសមរភូមិនោះ តែមីស្សុងរបស់លោកច្រើនតែមីស្សុងនៅក្នុងមុងរបស់ពួកស្រីផ្កាមាស...,

លោកផែលបើកភ្នែកធំ ៗ ដូចគូក អ្នកស្រីដឹងថាដាក់ចំចំណុចខ្សោយដែលលោកផែលរើលែងរួចហើយ ក៏ជាន់ថែម :

- លោក ! ឥឡូវនេះល្បីសម្បើមហើយ រូបលោកក៏ដូចជាពួកអស់លោកធំ ៗ ឯទៀតកំពុងតែប្រណាំងប្រជែងគ្នាប្រព្រឹត្តអំពើមិនគប្បីរបៀបប៉ោ ស្រី-ស្រា ថ្ងៃណាក៏ឃើញតែរវើរវែក . . . ថ្ងៃណាក៏ឃើញតែបើកឡានដឹកស្រីខូច . . . អាកប្បកិរិយារបស់លោកបែបនេះ តើវាសមនឹងតួនាទីរបស់លោកដែលមានបណ្ដាសក្ដិខ្ពង់ខ្ពស់នោះដែរឬ ?..

- ម៉ាក់វា ! (លោកផែលពោលកាត់ ; ឯងកុំចង់ឲ្យដំបូន្មានដល់ប្ដីណា៎ះ ! សព្វថ្ងៃនេះប្ដីមានកិច្ចការច្រើនណាស់ ! ក្នុងការធ្វើសង្គ្រាមមានក រលំបាកវេទនា និង នឿយហត់គ្រប់ជំពូក ដើម្បីបន្ធូរបន្ថយបរិយាកាសនោះ វាតែងមានការសប្បាយលេងសើចខ្លះមិនខានឯងមិនយល់ទាល់តែសោះឬ របបសាធារណរដ្ឋយើងនេះ ជារបបមានសិទ្ធិសេរីភាពបរិបូណ៌និងសម្បូណ៌សប្បាយគ្រប់យ៉ាង . . . ។

- ខ្ញុំយល់ហើយលោក ! សេរីភាពឥតព្រំដែន ! សម្បូណ៌សប្បាយក្លាយចង់ឆ្កួត !.. ហើយក៏ពុករលួយដល់ឆ្អឹងដែរ !



- ឈប់និយាយម៉ាក់វា ! (លោកផែលពោលឡើងតឹងសរសៃក) និយាយរបៀបនេះមិនមែនចំណេញទេណា៎ះ !.. ដឹងទេ ពួកអ្នកតស៊ូកំពុងតែធ្វើការឃោសនាបរិហាររដ្ឋាភិបាលស្រោចស្រង់ជាតិ បើឯងលើកយករឿងពុកមាត់ពុកចង្ការបស់អស់លោក និង របស់ប្ដីមកបកអាក្រាតវាមិនខុសអី ពីហែកទ្រូងឯងឲ្យក្អែកចឹកទេ !

- ខ្ញុំនិយាយ ! ក៏មិនមែនស្ថិតនៅក្នុងគោលបំណងអាក្រាតដែរណា៎លោក !

លោកផែលពោលកាត់ដោយសម្ដីធំ ៗ :

- ខ្ញុំស្ដាប់បានហើយ ! ឈប់និយាយទៅ !.. ឈប់ទៅ ! ទុកឱកាសឲ្យប្ដីបានស្រួលចិត្តផង !..

លោកផែលបោះសម្ដីរួច ក៏ដើរចេញទៅរកបន្ទប់ទឹក ។ ឯអ្នកស្រីស្ថិតនៅក្នុងសភាពស្ងប់ស្ងៀមមួយស្របក់ ទើបក្រោកទៅចាត់ចែងអ្នកបំរើឲ្យរៀបចំបាយទឹក ។

*

* *

ព្រឹកឡើងលោកផែលរៀបចំខ្លួនប្រាណចុះចេញពីគេហដ្ឋាន ដើម្បីចេញទៅធ្វើការតាមទម្លាប់ធម្មតា ។ ខណៈនោះគេឃើញនាយសនចូលមកគោរពលោកផែលទាំងព្រលឹម ។ ជននេះនិយាយនឹងនាយសនបន្តិចបន្តួច ក៏ឡើងរថយន្តចេញទៅបាត់ ។

ពេលនោះ អ្នកស្រីម្ចាស់ផ្ទះក្រឡេកមកឃើញនាយសនដែលកំពុងតែឈរតាមមើលដំណើរចោរហ្វាយនាយ ក៏បន្ទីហៅឲ្យកាប៉ូរ៉ាល់នេះឡើងទៅជួបគាត់មួយរំពេច :

– សន ! . . . សនឯងមានការអី បានជាមកជួបលោកប្រុសរបស់ឯងទាំងព្រលឹមនេះ ?

សនពោលឡើងក្នុងទឹកមុខស្មើ :

– បាទ លោកស្រី . . . ខ្ញុំគ្មានការអីទេ . . . មកជួបគេជាគុណ ព្រោះលោកត្រូវការនាំរូបខ្ញុំទៅធ្វើការនៅកន្លែងណាទៀត . . .

– គ្មានទៅបេសកកម្មឯណាទៀតទេ ! ( អ្នកស្រីបោះសម្ដីគំរោះគំរើយ ) ប៉ុន្មានថ្ងៃនេះលោកផាប់ប្រជុំរហូត !.

បាទ ! អញ្ចឹងខ្ញុំបាទសូមលាទៅវិញ . . .

– ឈប់ ! . . : ខ្ញុំសួរសនឯងបន្តិច សនឯងនេះពូកែដឹកញីបន្សំឈ្មោលណាស់ !. . . មើលធ្លាប់នាំប្តីរបស់អញទៅខិលខូចនៅកន្លែងណាខ្លះ ?

កាលអ្នកស្រីចុចសួរដូច្នេះ សនឡើងភ្នែកមូលដូចកាក់ ។ តាមពិតសនខ្លាចអ្នកស្រីនេះផងខ្លាចអំណាចលោកសក្តិបីផែលទៅទៀត ។ សនគិតថា បើឆ្លើយត្រង់ពិតជាត្រូវគ្នោងមិនខាន បើភូតក៏គង់ត្រូវមាត់ដែរតែអាចកែក្ដៅខ្លួនបានខ្លះ ៖

– បាទ លោកស្រី . . .



– កុំសូវសមគួរនឹងអញច្រើនពេក ! ឆ្លើយម៉ោ !. .

– បាទ គ្មានដែល . . . ទេលោកស្រី . . .

– ហ៊ឹះ ! . . គ្មានដែល ! ? ញឹកញយណាស់អាសន អញតាមដានដឹងអស់ហើយ ! . . . កាលពីម្សិលមិញនេះ ក៏មានដឹកនារីម្នាក់មកពីសមរភូមិដែរ !

– ទេ ! ទេ ! ខ្ញុំបាទគ្មានដឹងទេ ! . .

– មិនបាច់ភូតភរអញទេ ! ពួកចិនច្បាររាំពោនិយាយប្រាប់អញអស់ហើយ ! ឥឡូវលោកប្រុសឯងយកនារីនោះទៅលាក់ឯណា ? ប្រាប់ម៉ោ !

សនយល់ថាអ្នកស្រីនេះប៉ិនប្រសប់ឆរឲ្យធ្លាក់រឿង គេនឹកឃើញភ្លាមឆ្លើយភ្លែត :

– អ៊ុំ បាទ ! . . .លោកស្រីប្រហែលជាច្រឡំប្រពន្ធទាហានម្នាក់ដែលសុំដោយសាររថយន្តមកលេងបងប្អូននៅភ្នំពេញ . . .

– ប្រពន្ធទាហានណា ?

– ខ្ញុំបាទ មិនបានចាប់ភ្លឹក នឹកសួរដល់ឈ្មោះរបស់គេដែរ . . . ព្រោះគេទាក់ទងនឹងលោកប្រុស . . .

– អឺ !.. និយាយឲ្យត្រង់ណ៎ា . . . រឿងនេះ បើថ្ងៃក្រោយទៅអញរកឃើញថាឯងបានសមគំនិតទៅលើផ្លូវខិលខូច ឯងគ្មានពេលបាន

ឡើងផ្ទះអញទៀតទេ ... អាសន ! ឈប់នាំប្ដីរបស់អញទៅប្រព្រឹត្តអំពើថោកទាប !.., ស្ដាប់បានទេ ?

\- បាទ !..

\- ទៅ ! ចុះចេញពីផ្ទះអញទៅ !

សនបោះជំហានចុះត្រុក ៗ មកវិញ មិនខុសអំពីឆ្កែអង្គែសុីដែលនៅបំរើម្ចាស់ហើយត្រូវគេមិនបានយកចិត្តទុកដាក់ថែទាំ បែរជាដេញវាយផេរទៅវិញ ។ សននឹកចង់អស់សំណើចត្រង់ពាក្យសម្ដីអ្នកស្រីនេះព្រមានដល់ខ្លួនថា ជាមនុស្សមានសិទ្ធិនាំប្ដីរបស់គាត់ទៅប្រព្រឹត្តអំពើថោកទាប ពាសវាលពាសកាល .. គឺតទៅសម្ដីអ្នកធំតែងមានអានុភាពគ្របសង្កត់លើអ្នកតូចជានិច្ច ។

*

* *

ម៉ោងប្រាំពីរយប់ ... គឺម៉ោងដែលនាងសម្ផស្សចាប់ផ្ដើមកើតការតប់ប្រមល់ខ្វល់ចិត្តនិងព្រួយបារម្ភជាទីបំផុត ។ ពីរថ្ងៃ ពីរយប់ហើយគេបានយកនាងមកបង្ខាំងទុកក្នុងបន្ទប់មួយដ៏តូចនៅលើផ្ទះនាយសន ។ ពិតមែនថា ទីនេះជាគេហដ្ឋានរបស់មនុស្សរស់នៅ ប៉ុន្តែការដែលគេបង្ខាំងទុកមិនឱ្យដើរហើរទៅណាបាននោះ ក៏មិនខុសពីទីឃុំឃាំងអ្នកទោសដែរ ។

ក្នុងរយៈពីរថ្ងៃកន្លងមកនេះ សម្ផស្សបានពិនិត្យពិចារណាមើល



Phnom-Penh University
LIBRARY

អាកប្បកិរិយារបស់នាយស[illegible]ដែលនៅថែរក្សាការពាររូបនាងវិស័យដូចជាឆ្មាំ ឬ អ្នកគង្វាលត្រូវទទួលបញ្ជាពីម្ចាស់ឱ្យមើលខុសត្រូវយ៉ាងម៉ឹងម៉ាត់ ។ សូម្បីតែនាងចេញទៅបត់ជើង ក៏គេតាមទៅអង្គុយចាំការពារដែរ ។ សម្ផស្សនឹកឃើញថា ខ្លួនប្រាកដជាគេចាត់ទុកថាអ្នកមានទោស ប៉ុន្តែហេតុយ៉ាងម៉េចបានជាគេ មិនយកទៅកន្លែងឃុំឃាំង ឬ គេមិនមកសួរចម្លើយសោះ ? ផ្ទុយទៅវិញ នាងបែរជាបានទទួលពាក្យបបោសអង្អែលសតិអារម្មណ៍តាមរយៈនាយសនថា លោកផែលមានការអាណិតអាសូរនាងណាស់!. ស្រឡាញ់នាងណាស់ !..។ សម្ដីទាំងនេះនាងយល់ថាជាការសូចិត្តឱ្យទោទន់ ដើម្បីផលប្រយោជន៍អ្វីមួយ . . . ។

និយាយអំពីជនមានឋានៈអនុសេនីយ៍ឯកនោះ ទោះបីធ្មេចភ្នែកសម្ផស្សនៅតែនឹកឃើញនិងចាំបាន កាលធ្វើដំណើរតាមរថយន្ត ជននោះតែងបញ្ចេញទឹកមុខញញឹមរកនាងជាញយ ៗ គឺជាភាពញញឹមមួយគួរឱ្យខ្លាច ! . . តែនាងបានប្រកាន់ឥរិយាបថនឹងហ្ន៎ និងស្ថិតនៅស្ងប់ស្ងៀមជានិច្ច ។ រហូតមកទល់ពេលនេះ នឹកឃើញមុខលោកផែលនាងមានការតក់ស្លុតមិនតិចឡើយ ។

ភ្លៀងរលឹមស្រិច ៗ . . . នៅក្នុងព្រៃចេកភូមិរបស់នាយសនតែសំឡេងកូនក្ដាត់និងគ្រាតយំក្រេតក្រេត ៗ ឯលើគេហដ្ឋានមានសភាពស្ងាត់ជ្រងំដូចខ្ទមអ្នកតាស្ថិតនៅក្នុងព្រៃស្មសាន ។ សម្ផស្សអង្គុយ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

សំកុកកើតទុក្ខតែម្នាក់ឯង នៅក្រោមពន្លឺភ្លើងអំពូលក្រហមព្រាងៗ ដែលផ្តល់ដោយបាមពលអគ្គិសនីយ៉ាងខ្សោយ ។

លំដាប់នោះស្រាប់តែសម្ផស្សឮស្នូរគោះទ្វារបន្ទប់ផ្ទួនៗគ្នា នាងចាប់ ព្រឺក្បាលខ្វាក !នាងរិះគិតហើយចាប់ភ័យខ្លាចដល់ព្រឹត្តិការណ៍មួយដែលនឹងកើតឡើងយ៉ាងអាក្រក់ មិនដឹងជារកវិធីណាដោះស្រាយ ។

តុក! តុក !.. សំឡេងគោះទ្វារម្តងទៀតព្រមនឹងសម្តីបន្លឺមកពីក្រៅ !

- បើកទ្វារ !..

សម្ផស្សក្រោកឡើង បោះជំហានសន្សឹមៗ ទៅឈរអែបមាត់ទ្វារ គិតបន្តិច រួចដាច់ចិត្តរាចាសួរទៅវិញទាំងសំឡេងញ័រ ៗ :

- អ្នកណា ?

- ខ្ញុំណា៎នាង ... បើកទ្វារឡើង !

សម្ផស្សចាប់បុកពោះភឹប ៗ ព្រោះឮសូរសៀងនេះ នាងនៅចាំបានច្បាស់ គឺជាសម្តីរបស់លោកផែល ។ នាងឈរពិចារណាមួយរយៈខ្លី តើលោកផែលមកធ្វើអ្វីថ្មើរនេះ ? ... ពិតជាមានហេតុអាក្រក់កើតឡើង! ឱ!..បើសិនជាលោកចូលមកយកនាងទៅធ្វើទារុណកម្ម ឬមានបំណងប្រាថ្នាដោយប្រការអ្វីមួយមកលើរូបនាង នាងគ្មានមធ្យោបាយអាចការពារខ្លួនបានទេ នាងមានគំនិតតែម្យ៉ាង គឺនឹងលើកដៃសំពះអង្វរករលន់តួលោកផែលសុំឱ្យគាត់អនុគ្រោះដល់រូបនាង នាងយល់ថាលោក



ផែលជាខ្មែរដែលមានវ័យចាស់ទុំទៅហើយ យ៉ាងហោចណាស់ក៏គាត់មានសីលធម៌នៅក្នុងខ្លួន អាចយោគយល់សន្តោសប្រោសប្រណីដល់រូបនាងជានារីខ្មែរដែរ ។ គិតឃើញដូចនេះ សម្ផស្សក៏ដាច់ចិត្តដកគន្លឹះទ្វារ។ លុះទ្វាររបើកឡើង នាងឃើញ លោកផែលស្លៀកពាក់ ក្នុងភាពស៊ីវិល ឈរញញឹមមករកនាងនៅជិតបង្អួច ។

- សម្ផស្ស ...

លោកផែលពោលឡើងព្រមជាមួយនឹងកែវភ្នែកប្រារព្ធលើរង់ភ័ក្ត្រ-យុវតី ដៃម្ខាងរបស់គាត់រុញទ្វារបិទទៅវិញ ។ សម្ផស្សដាក់មុខចុះគេចចេញពីខ្សែភ្នែកលោកផែលនិងឆ្លើយ :

- ចា៎ស លោក ...

- នាងកំពុងគិតអីនេះ ? (លោកផែលសួរទាំងញញឹម) ។

- ចា៎ស !.. គ្មានគិតអីទេលោក ...

លោកផែលបោះជំហានយឺតៗ ចូលទៅជិតមាណវី តែនាងចេះតែឈានថយទៅក្រោយ បេះដូងរបស់នាងចាប់លោតខុសចលនាធម្មតា ហើយទឹកមុខរបស់នាងក៏ចាប់ប្រែស្លេកស្លាំង ដូចគ្មានឈាមមួយដំណក់សោះ ។ សម្ផស្សថយទៅ ៗ រហូតទល់នឹងគៀនជញ្ជាំងក៏យកដៃឱបទ្រូង ...

- សម្ផស្ស ! (លោកផែលនិយាយក្នុងទឹកមុខស្រស់ស្រាយបង្ហាញឱ្យយុវតីទុកចិត្ត ) មើចក៏នាងចេះតែថយចេញពីខ្ញុំអញ្ចឹង ចូលមក

ផិតខ្ញុំម៉ោ ! . . អង្គុយនៅលើគ្រែនេះ យើងនិយាយគ្នាលេងបន្តិច ។

- ទេលោក ! ( សម្ផស្សលើកដៃសំពះ ) ខ្ញុំមិនហ៊ានអង្គុយជិតលោកទេខ្ញុំខ្លាចលោកណាស់ !

- ហ៊ឺា . . . កុំខ្លាច ! ខ្ញុំមិនមែនជាយក្ស ឬ សត្វខ្លា ចូលមកខាំនាងឯណា ?

- ចាស ! តែខ្ញុំជាអ្នកក្រ មិនសក្តិសមនឹងអង្គុយជិតលោក ដែលមានឋានៈខ្ពង់ខ្ពស់នោះទេ ។

- អ៊ឺ ហ៊ឺា ហ៊ឺាស . . . ខ្ញុំមិនមែនជាមនុស្សប្រកាន់ខ្លួនប្រាណទេណ៎ានាង !

- ចាស . . . បើលោកមានការអី សូមមានប្រសាសន៍មកចុះ !

- អង្គុយលើគ្រែសិនមកសម្ផស្ស ! ខ្ញុំនិយាយបន្តិច ព្រោះខ្ញុំពេញចិត្តនឹងអត្តចរិតសុភាពរាបសាររបស់នាងណាស់ណ៎ា ខ្ញុំមិនដែលពេញចិត្តនឹងនារីណាដូចនាងទេ . . . ខ្ញុំអាណិតនាងបានជាខ្ញុំយកនាងមកទុកឱ្យផុតពីការធ្វើទារុណកម្មរបស់ពួកទាហាន . . . ខ្ញុំនឹងជួយនាងឱ្យរួចពីទុក្ខទោសណ៎ា បើសិនជានាងព្រមស្ម័គ្ររួមរ័ត្នជាមួយខ្ញុំ ។

និយាយមកដល់ត្រឹមនេះ លោកផែលលូកដៃស្រវាចាប់នាងសម្ផស្ស តែយុវតីប្រញាប់ប្រាសគេចទៅរកកៀនជញ្ជាំងម្ខាងទៀត ។ នាងភិតភ័យតក់ស្លុតរន្ធត់ញ័រចំប្រប់ដូចកូនសត្វត្រូវភ្លៀងខ្យល់ ។ នាងមិននឹកស្មានសោះថា លោកផែលដែលមានបណ្ដាសក្តិខ្ពង់ខ្ពស់និងមានវ័យចំណាស់ទៅហើយ ហ៊ានទម្លាយនូវសម្ដីប្រលោមចិត្តនាងប្រាសចាកសីលធម៌បែបនេះសោះ ។ គិតទៅពួកអស់លោកធំៗ អ្នកមានអំណាចប្រាក់កាសនៅសម័យនោះ មិនបានគិតដល់សេចក្ដីថ្លៃថ្នូររបស់នារីភេទទេ គេចាត់ទុកថា នារីភេទជាឧបករណ៍មួយសម្រាប់បំរើសេចក្ដីស្រើបស្រាលខាងផ្លូវកាមតណ្ហារបស់ខ្លួនប៉ុណ្ណោះ ។



- លោក ! ( សម្ផស្សរាចាទាំងញ័រមាត់ប៉ិប៉ុប ) ខ្ញុំសូមអង្វរ . . សូមលោកអាណិតខ្ញុំ ខ្ញុំព្រមរួមរក្សស្ម័គ្រនឹងលោកមិនបានទេ លោកមានអាយុច្រើនប្រៀបបានឪពុកខ្ញុំទៅហើយ . . .

សម្ផស្សនិយាយបានប៉ុណ្ណេះ ក៏ចាប់ខ្សឹកខ្សួល ។ លោកផែលព្យាយាមលួងលោមនាងតទៅទៀត :

- កុំគិតអញ្ចឹងណ៎ាសម្ផស្ស សេចក្ដីស្នេហាមិនប្រកាន់ថាវ័យចាស់ឬក្មេងទេ នាងព្រមទទួលខ្ញុំជាប្ដីទៅ ខ្ញុំនឹងឱ្យនាងបានសុខកាយសប្បាយចិត្តរហូតមួយជីវិត ។

- ទេលោក ! ខ្ញុំព្រមធ្វើជាប្រពន្ធលោកមិនកើតទេ ! ខ្ញុំយល់ថាលោកមានប្រពន្ធហើយ ។ លោកក៏មិនខ្វះស្រីសំរាប់បំរើសេចក្ដីសប្បាយដែរ !

សម្ផស្សរាចាផងព្រមទាំងងាកទៅរកមាត់ទ្វារ តែលោកផែលស្ទុះទៅឈរពាំងខ្ទាស់គន្លឹះទ្វាររួចស្រវាចាប់ដៃនាងទាញមកលើគ្រែ :

\- សម្ផស្ស ! នាងត្រូវតែព្រមរួមរក្សនឹងខ្ញុំក្នុងយប់នេះណាៈ . . . នាងកុំភិតភ័យ ! នាងគ្មានខាតបង់អ្វីទេ គ្រាន់តែបណ្ដោយខ្លួនឲ្យខ្ញុំ បន្ដិចប៉ុណ្ណោះ នាងនឹងបានសប្បាយចិត្តហើយរួចខ្លួនភ្លាមៈ..ហ៊ីនែបង ឲ្យលុយប្រាំរយរៀល យកទុកចាយវាយទៅណា៎ . . .

លោកផ្ដែលពោលផង ក៏ទាញក្រដាស់ប្រាក់ប្រាំរយដាក់ទៅក្នុង បាតដៃនាងសម្ផស្ស តែនាងរលាស់ចេញ :

\- លោក ! លោកកុំធ្វើដូចនេះ ខ្ញុំជាអ្នកក្រ ពិតមែនតែមានកា ខ្វះខាតតែខ្ញុំមិនត្រូវការប្រាក់កាស់លោកទេ ! សូមលោកទុកប្រាក់នេះ ទៅទិញផ្កាស្រីផងទៃទៀតចុះ !

\- ហ៊ាំ ហ៊ាស...ខ្ញុំមិនដែលជួបប្រទះសោះស្រីណាមិនស្រឡាញ់ មាសប្រាក់ ?

\- ចាស ! តែប្រាក់លោកជាភ្លើង យកមកទិញផ្លូវកិត្តិយសរបស់ ខ្ញុំ ខ្ញុំមិនមែនជាទំនិញទេ ! ... ខ្ញុំមិននឹកស្មានសោះថាលោកជាមនុស្ស មានឋានៈខ្ពស់ តែបែរទៅជាមានគំនិតអាក្រក់មើលងាយមើលថោ អ្នកក្រដល់ម្លឹង !

\- នែ៎សម្ផស្ស ! (លោកផ្ដែលដែលពីមុនមកខំប្រើទឹកមុខស្រ ញ៉ញឹម ប្រែទៅជាតឹងឡើងមុខមាំគួរឲ្យខ្លាច) នាងត្រូវដឹងថា នាងស្ថិ នៅទីណាហ្ន៎ ហើយក្នុងស្ថានភាពដូចម្ដេច ? ពេលនេះ បើនាងឯងមិ



ព្រមឲ្យយើងដោយស្រួលទេ ក៏មិនអាចគេចរួចពីក្រញាំដៃយើងដែរ យើងត្រូវតែចាប់បង្ខំនាងដាច់ខាត !

និយាយផុតមាត់ស្ទើរមិនទាន់ ខ្លាតញាស់ក៏លោតទៅសង្គ្រុបស្រវា ឱបយុវតីទាំងក្រហល់ក្រហាយ ហើយចាប់ផ្ដួលទៅលើគ្រែ ទាញហែក ហូរសម្លៀកបំពាក់ប៉ុនប៉ងរំលោភ ... ។ សម្ផស្សខំរើបម្រះនិងប្រវាយ ប្រតប់ . . . ខណៈនោះ មានសំឡេងគោះទ្វារយ៉ាងញាប់រន្ថើននិងមាន សំឡេងបន្លឺហៅយ៉ាងទាន់ហន់ :

\- តេជគុណៗ ! . . . សូមបើកទ្វារប្រញាប់ !. . . បើកទ្វារ ឡើង :

លោកផ្ដែលដែលហាក់ដូចជា នឹង ត្រូវបានបំពេញគោលបំណង ហើយស្រាប់តែមានចង្រៃចៃដន្យចូលមកដល់ ធ្វើឲ្យគាត់កើតមួម៉ៅក្ដៅ ក្រហាយ ក៏ស្ទុះទៅសួរ :

\- អាណា ?

\- បាទ ខ្ញុំបាទទានប្រោស !

\- អាសនឬ ?

\- បាទទាន !

\- ចុះអាឡែង មកធ្វើខ្លាចលងអី ដឹងអញរៀបចំនឹងចាត់ការទេ?

\- មិនបានទេ ទានប្រោស ! សូមបើកទ្វារអញ្ជើញចេញមកសិន!

លោកផែលឮសម្ដីនាយសននិយាយ បែបដាច់ខាតសម្បើមណាស់ក៏ដាច់ចិត្តបើកទ្វារចេញមកជួបទាំងទើសទ័ល :

- មានរឿងអីអាសន ?

- បាទ លោកស្រីអញ្ជើញមកដល់ហើយ ( សនពោលប្រាប់តិចៗ )

- ហ៊ាក ! គេហ៍មកជាមួយអ្នកណា ?

- បាទ ... មកជាមួយអាប៉ាកាណា កូនប្រុសរបស់តេជគុណ ។

- អាឆ្កួត ! អញឱ្យអាឯងនៅយាមផ្លូវ ម៉េចក៏ឱ្យគេហ៍ចូលមកបាន ! ក្រែងអាឯងរវល់តែដេកពីរនាក់ប្ដីប្រពន្ធដែរទេឬ ?

- អត់ទេទាន បើខ្ញុំដេកធ្វើម៉េចដឹងលោកស្រីចូលមក !

- អញ្ចឹង អាឯងបានប្រាប់គេហ៍ថាអញនៅទីនេះ ?

- អត់ទេ តេជគុណ លោកស្រីមិនដឹងពីណា ស្រាប់តែឃើញអាប៉ាកាណាជិះម៉ូតូឌុបគាត់មកឈប់នៅផ្ទះគេខាងណោះ រួចគាត់លួចដើរមកផ្ទះខ្ញុំនេះដោយសម្ងាត់ ខ្ញុំបានក្រឡេកឃើញភ្លាម ក៏រត់ភ្លែតឡើងតាមជណ្ដើរក្រោយមកប្រាប់តេជគុណនេះ !

នាយសននិយាយស្ទើរផុតមាត់មិនទាន់ ស្រាប់តែមានសំឡេងបន្លឺហៅនៅច្រកទ្វារមុខ :

- ប៉ាវា ! ប៉ាវាបើកទ្វារ !



លោកផែលចាប់បុកពោះភ័យស្លន់ស្លោ ងាកឱ្យបដាក់នាយសនៈ

- ហ៊ឺ អាសន ! គេហ៍ឡើងមកហើយអាជម្ងឺយ៍ គិតយ៉ាងម៉េចជួយអញផង ។

- រឿងនេះ មិនស្រួលទេទាន ( នាយសនឱ្យយោបល់ ) តេជគុណត្រូវចេញទៅដោះស្រាយជាមួយលោកស្រី ឯខ្ញុំលួចបង្គួចនាងសម្ផស្សចេញតាមជណ្ដើរក្រោយទៅក្រៅសិន ។

- អើ អើ ... ឯងចាត់ចែងឱ្យរហ័សទៅអញ្ចឹង !

នាយសនក៏ភិតភ័យណាស់ដែរ ព្រោះខ្លាចរឿងនេះរាលដាលដល់ខ្លួនក៏ស្ទុះចូលទៅនិយាយប្រាប់នាងសម្ផស្សតិចៗ រួចនាំនាងចុះចេញពីផ្ទះជាបន្ទាន់ ។ ឯលោកផែលក៏ដើរទៅឈរអែបនៅទ្វារមុខ ។

- ប៉ាវា បើកទ្វារ ! បើកភ្លាមឡើង ! .. ម៉េចនៅសម្ងំអីខាងក្នុងនោះមិនព្រមបើកទេឬ ? ... បើមិនបើក ខ្ញុំដុតផ្ទះនេះកំទេចឥឡូវ-ហ្នឹង !

ឮសម្ដីភរិយាបែបមិនស្រួល លោកផែលក៏ដាច់ចិត្តយកដៃកេះកុងតាក់ភ្លើងឱ្យភ្លឺឡើងរួចដោះគន្លឹះទ្វារឱ្យរបើក ។ គេឃើញអ្នកស្រីស្ទុះឡើងមក ដោយមានកាន់កាំភ្លើងខ្លីមួយភ្ជង់ចុងកាណុងផង ។

- ហ៊ឹះ . . . ហោស្ទើរបែកស្រុក ចេះសម្ងំទៅកើត ប៉ាវាឯងនៅធ្វើអីលើផ្ទះនេះ ?

- អត់ ... អត់ធ្វើអីទេម៉ាក់វា ( លោកផែលឆ្លើយតឹបតុប )

– អត់ធ្វើអី ? . . . ចុះមកផ្ទះនេះធ្វើអ្វី ?

សំនួរចោទឡើងព្រមជាមួយទឹកមុខក្រមួររបស់អ្នកស្រី ធ្វើឲ្យលោកផែលទាល់ប្រាជ្ញទៅឈរអេះអុញបន្តិច ទើបឆ្លើយដោះខ្លួនទាំងប្រថុយ ៖

– ខ្ញុំទៅប្រជុំ... ចេញមកវិញចូលហាងផឹកស្រាស្រវឹង ក៏នឹកចង់បើកឡានមកលេងនាយសន លុះមកដល់ផ្ទះនេះប្រះដេកទៅក៏ស្រាប់តែលក់មិនដឹងខ្លួនណ៎ាម៉ាក់វា . . .

អ្នកស្រីស្ដាប់ទៅមិនទំនងក៏បើកភ្នែកធំៗ ស្ទើរប៉ុនពងមាន់ ៖

– អ៊ឺ . . . បានះដូចជាវាឯងនេះ ដើរដេកតាមផ្ទះគេដូចពួកបាតផ្សារអញ្ចឹង ? ខ្ញុំដឹងគំនិតអស់ហើយ លាក់ឡានទុកនៅឯណោះ! .. ម្ចាស់មកដេកឯណេះ! . . ឥឡូវនិយាយប្រាប់ខ្ញុំឲ្យត្រង់ ! បើមិនប្រាប់ទេ តែខ្ញុំរករឿងហេតុឃើញ ប្រយ័ត្នមានរឿងរ៉ាវខ្មាសគេ !

– គ្មានអីទេ ម៉ាក់វា ! . .

អ្នកស្រីខាំមាត់សង្កៀតធ្មេញ ហើយចាប់ដើរឆែកឆេរពេញក្នុងផ្ទះ ។ លុះចូលបន្ទប់ក៏ប្រទះឃើញកាំភ្លើងខ្លីរបស់ប្ដីគាត់ជ្រុះនៅលើកន្ទេល ប្រាក់ជាំរយរៀល និងឃ្នាបសក់នារីមួយ ។ គាត់ចាប់ប្រមូលយករបស់ទាំងនោះហើយកាន់កាំភ្លើងចេញមកស្រដីដាក់ប្ដី :

– ស្អីនេះ ភស្ដុតាងច្បាស់ក្រឡែត ! កាំភ្លើងរបស់លោក ប្រាក់ ឃ្នាបសក់ របស់នារី ! . .   លោកច្បាស់ជាយកស្រីមកដេកនៅជាមួយ ! . . ឥឡូវនារីនោះនៅឯណា ?



– អត់ . . . អត់មាន . . .

– អត់មាន ហ៊ឹះ ! . . អាសន ! ( អ្នកស្រីស្រែកឡូឡាឡើង ) អាឯងពង្រត់នារីនោះទៅឯណា យកមកឲ្យអញ !

– ម៉ាក់វា . . . កុំមាត់កអី ខ្មាសគេ...( លោកផែលអង្វរ) ។

– យើ ! ខ្មាសគេ ! . ដល់តាមដានទាន់អញ្ចឹង លោកចេះសារភាពថាខ្មាសគេ ! . . . លោកមានគំនិតក្រឡិចក្រឡុចភូតកុហកខ្ញុំច្រើនលើសច្រើនសា និយាយថាទៅប្រជុំ !. .ទៅបេសកកម្ម !. . គឺបេសកកម្មលោករបៀបនេះ !

– ម៉ាក់វា ឈប់មាត់ទៅ ខ្ញុំខុសម្ដងហើយណ៎ា

– មិនមែនម្ដងទេ !.. លោកដើរលេងសើចរាល់ថ្ងៃ ! ប៉ុណ្ណឹងបានហើយ ឈប់មាត់ទៅ !... ខ្ញុំខ្មាសគេណាស់ !

– ចេះខ្មាសគេដែរអ៊ឺះ ? ...ឥឡូវទៅ ! សូមអញ្ជើញលោកទៅផ្ទះ ៖

ព្ទបញ្ហាដាច់ខាតនេះ លោកផែលរកពាក្យអ្វីប្រកែកមិនបាន តែនៅឈរអល់អែកមិនចង់ឈានជើងចុះ ទាល់តែអ្នកស្រីដាក់ផែនការក្ដៅៗ៖

– មើច ? .. នៅស្រណោះនារីនោះដល់ណាទៀត ? លោកទៅឬមិនទៅ ? បើនៅរឹងទទឹង ខ្ញុំបាញ់ដាច់ស្លឹកត្រចៀកឥឡូវហ្នឹង !

– អ៊ើ !. .ម៉ាក់វា ( លោកផែលភ័យប្រញាប់លើកដៃវា) ឯងប្រុង